# ការជូនដំណឹង និង ការលះបង់សិទ្ធិ

## ការជូនដំណឹងរបស់លោក មាស មុត អំពីចេតនាប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយ និង ការលះបង់ចោលនូវទំនាស់ផលប្រយោជន៍ដែលអាចកើតមានជាសក្តានុពល

ខ្ញុំ មាស មុត យល់ដឹងយ៉ាងពេញលេញថា ខ្ញុំជាជនជាប់សង្ស័យនៅក្នុងសំណុំរឿង ០០៣ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខ្ញុំបានទទួលដំណឹង តាមរយៈលោកស្រី Nisha Valabhji នៃអង្គភាពគាំពារការការពារក្តីអំពីឋានៈនិងសិទ្ធិរបស់ខ្ញុំ។ ខ្ញុំមានបំណងពេញលេញក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយរបស់ខ្ញុំ។ ខ្ញុំគ្មានចេតនាក្នុងការឆ្លើយនឹងសំណួរនានាក្នុងនាមជាសាក្សីនៅក្នុងសំណុំរឿង ០០២ ឬក៏ក្នុងនាមជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ ឬ ជាសាក្សីក្នុងសំណុំរឿង ០០៤ ឡើយ។

ខ្ញុំត្រូវបានប្រាប់ដោយលោកស្រី Valabhji ថា ខ្ញុំមានសិទ្ធិទទួលបានកិច្ចការពារក្តីតាមផ្លូវច្បាប់អនុលោមតាមមាត្រា ២៤ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំបានជូនដំណឹងដល់លោកស្រី Valabhji ថា ខ្ញុំជ្រើសរើសលោក អាង ឧត្តម ដើម្បីធ្វើជាមេធាវីការពារក្តីរបស់ខ្ញុំ។ ខ្ញុំត្រូវបានគេជូនដំណឹងថា ខ្ញុំមានសិទ្ធិទទួលបានមេធាវីអន្តរជាតិ ខ្ញុំសូមជ្រើសរើស លោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. KARNAVAS)។ ដោយយល់ដឹងយ៉ាងពេញលេញថា បច្ចុប្បន្ន មានការស៊ើបអង្កេតប្រឆាំងនឹងរូបខ្ញុំ និង ដោយយល់ដឹងយ៉ាងច្បាស់ អំពីសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានកិច្ចការពារក្តីតាមផ្លូវច្បាប់ ខ្ញុំ ដោយស្ម័គ្រចិត្ត ដោយយល់ដឹងច្បាស់ និង ដោយគ្មានមន្ទិលសង្ស័យ សុំលះបង់សិទ្ធិទាក់ទងនឹងលទ្ធភាពមានទំនាស់ផលប្រយោជន៍ ដែលអាចកើតមានឡើងដោយសារកិច្ចការពារក្តីលោក អៀង សារី ដោយលោក អាង ឧត្តម និង លោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. KARNAVAS) នៅក្នុងសំណុំរឿង ០០២ ហើយលើសពីនេះ សុំបញ្ជាក់អះអាងឡើងវិញអំពីចេតនារបស់ខ្ញុំចង់ទទួលបានកិច្ចការពារក្តីពីលោក អាង ឧត្តម និង លោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. KARNAVAS) ។

ជាកិច្ចបន្ថែមទៅលើការលះបង់សិទ្ធិរបស់ខ្ញុំនេះ ខ្ញុំមានបំណងសុំជូនដំណឹងដល់ អវតក ថា ខ្ញុំមិនធ្លាប់ជាសមាជិកនៃក្រសួងការបរទេស និង មិនដែលធ្លាប់រាយការណ៍ទៅក្រសួងនេះទេ។ លោក អៀង សារី ក៏មិនដែលធ្លាប់ជាមេដឹកនាំរបស់ខ្ញុំ ឬ មិនធ្លាប់ជាអ្នកក្រោមបង្គាប់ខ្ញុំឡើយ។

សូមទទួលការគោរពអំពីខ្ញុំ

ភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១២

មាស មុត

# NOTICE AND WAIVER

## MEAS MUTH'S NOTICE OF INTENT TO EXERCISE RIGHT TO REMAIN SILENT AND WAIVER OF ANY POTENTIAL CONFLICT OF INTEREST

I, Mr. MEAS Muth, am fully aware that I am a suspect in Case 003 at the Extraordinary Chambers in the Courts of Cambodia. I have been fully advised of my status and rights by Ms. Nisha Valabhji of Defence Support Section. I fully intend to exercise my right to remain silent. I have no intentions of answering any questions as a witness in Case 002, as a suspect in Case 003, or as a witness in Case 004.

I have been informed by Ms. Valabhji that I am entitled to legal representation pursuant to Article 24 new of the Law on the Establishment of Extraordinary Chambers in the Courts of Cambodia for the Prosecution of Crimes Committed During the Period of Democratic Kampuchea. I informed Ms. Valabhji that I select Mr. Ang Udom to be my legal representative. I have been advised that I am entitled to an International Co-Lawyer, I select Mr. Michael G. KARNAVAS. With full knowledge that there is a current investigation against me and in full knowledge of my right to legal representation, I voluntarily, knowingly and unequivocally waive any conflict of interest that might exist as a result of Mr. Ang Udom and Mr. Michael G. KARNAVAS's representation of Mr. IENG Sary in Case 002, and further reaffirm my desire to be represented by Mr. Ang Udom and Mr. Michael G. KARNAVAS.

In further support of my waiver, I wish to inform the ECCC that I was not a member of the Ministry of Foreign Affairs and did not report to that Ministry. Mr. IENG Sary was neither my superior nor my subordinate.

Respectfully submitted,
Phnom Penh, 13 June, 2012

Meas Muth

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ជូនចំពោះ៖ លោក អាយសាក់ អ៊ីនឌេលី** (Issac ENDELY)

**ប្រធានអង្គភាពគាំពារការពារក្តី**

**កម្មវត្ថុ៖ សំណើសុំការចាត់តាំងមេធាវីការពារក្តី**

ខ្ញុំបាទ មាស មុត ជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ សុំស្នើដល់អង្គភាពគាំពារការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) មេត្តាតែងតាំងមេធាវីការពារក្តីមួយចំនួន សម្រាប់រូបខ្ញុំ ដើម្បីការពារសិទ្ធិរបស់ខ្ញុំ ទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និង តាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

នាដើមឆ្នាំនេះ ខ្ញុំបានដឹងអំពីការចោទប្រកាន់ប្រឆាំងនឹងខ្ញុំ និង ឋានៈរបស់ខ្ញុំជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣។ ក្រោយមក នាឆ្នាំដដែលនេះ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការពារក្តី បានមកជួបខ្ញុំ ដើម្បីពន្យល់អំពីតួនាទីរបស់អង្គភាពគាំពារការពារក្តី ដែលទទួលបន្ទុកផ្តល់ការគាំពារផ្នែកច្បាប់ដល់ជន សង្ស័យនានា ដែលត្រូវចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ខ្ញុំត្រូវបានគេផ្តល់ឱវាទថា ដោយសារខ្ញុំត្រូវបានគេចោទប្រកាន់ជាផ្លូវការដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក្នុងឋានៈខ្ញុំជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ ខ្ញុំមានសិទ្ធិទទួលបានមេធាវីមួយចំនួនតាមការជ្រើសរើសរបស់ខ្ញុំ រួមមានទាំងមេធាវីជាតិនិងអន្តរជាតិដោយឥតគិតថ្លៃ ក្នុងករណីដែលខ្ញុំមិនមានមធ្យោបាយគ្រប់គ្រាន់ដើម្បីជួលមេធាវីទាំងនេះ។

ខ្ញុំបានដឹងយ៉ាងច្បាស់អំពីសិទ្ធិរបស់ខ្ញុំជាជនសង្ស័យក្នុងសំណុំរឿង ០០៣។ ខ្ញុំសុំប្រើប្រាស់សិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់ខ្ញុំ ដោយស្ម័គ្រចិត្ត និង ដោយមានការយល់ដឹងយ៉ាងច្បាស់លាស់ ធ្វើការជ្រើសរើសលោក អាង ឧត្តម និង លោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. KARNAVAS) ជាសហមេធាវីការពារក្តីខ្ញុំ ដោយការជ្រើសរើសរបស់ខ្លួនខ្ញុំផ្ទាល់។ ខ្ញុំសុំស្នើដល់អង្គភាពគាំពារការពារក្តីមេត្តាធ្វើការតែងតាំងសហមេធាវីទាំងពីរូបនេះយ៉ាងឆាប់រហ័ស។

ភ្ជាប់មកជាមួយនេះ គឺជាការជូនដំណឹងរបស់ខ្ញុំ ស្នើសុំឲ្យមានការតែងតាំងលោក អាង ឧត្តម និង លោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. KARNAVAS) ដើម្បីការពាររឿងក្តីខ្ញុំ ដោយហេតុថា ខ្ញុំគឺជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ការលះបង់សិទ្ធិរបស់ខ្ញុំចំពោះទំនាស់ផលប្រយោជន៍នានាដែលអាចកើតមានឡើង។

សូមលោកទទួលយកនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១២

មាស មុត

**Kingdom of Cambodia**

**Nation Religion King**

Phnom Penh, 13 June 2012

To: Mr. Issac ENDELY
Chief of Defence Support Section

Re: REQUEST FOR ASSIGNMENT OF LEGAL ASSISTANCE

I, Meas Muth, a suspect in Case 003, request the Defence Support Section of the Extraordinary Chambers in the Court of Cambodia (ECCC) to appoint lawyers for me to protect my rights as provided by the Constitution of the Kingdom of Cambodia, the Agreement between the United Nations and the Royal Government of Cambodia and the Law on the Establishment of the ECCC.

Earlier this year I learnt of the charges against me and my status as a suspect in Case 003. Again later at the same year the Officer-in-Charge of the Defence Support Section visited me to explain the role of the Defence Support Section which is to provide legal support to any suspect charged before the ECCC. I have been advised that since I was officially charged by the Office of the Co-Investigating Judges and my status as a suspect in Case 003, I have rights to have lawyers of my own choosing including National and International for free of charge in case that I have no means to afford for retention of the lawyers.

I am now fully aware of my rights as a suspect in Case 003 and I voluntarily, knowingly and equivocally exercise my constitutional right to select Mr. ANG Udom and Mr. Michael G. KARNAVAS as my co-lawyers of my own choosing and request the Defence Support Section to appoint them immediately.

Attached is my notice requesting Mr. ANG Udom and Mr. Michael G. KARNAVAS to be appointed to represent me since I am a suspect in Case 003 and my waiver of any conflict of interest should any exist.

Respectfully Yours,

Meas Muth

# លិខិតលះបង់សិទ្ធិ

<u>ការលះបង់សិទ្ធិរបស់លោក អៀង សារី ទាក់ទងនឹងទំនាស់ផលប្រយោជន៍ដែលអាចមានជាសក្តានុពល</u>

ខ្ញុំ អៀង សារី តាមរយៈលិខិតនេះ សុំលើកលែងចោល ដោយស្ម័គ្រចិត្ត ដោយការយល់ដឹង និង ដោយឥតមន្ទិលសង្ស័យ នូវទំនាស់ផលប្រយោជន៍ជាសក្តានុពល ដែលអាចកើតមានឡើងដោយសារមេធាវីរបស់ខ្ញុំ គឺលោក អាង ឧត្តម និងលោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. Karnavas) ធ្វើកិច្ចការពារក្តីរបស់លោក មាស មុត។ ដើម្បីអនុវត្តការលះបង់ចោលនូវទំនាស់ផលប្រយោជន៍ជាសក្តានុពលនេះ ខ្ញុំយល់ដឹងយ៉ាងពេញលេញថា ខ្ញុំក៏នឹងលះបង់ចោលផងដែរនូវចំណុចបណ្តឹងឧទ្ធរណ៍ដែលអាចមានឡើង ទោះបីជាមានលក្ខណៈតូចតាចក្តី ដោយសារការអនុញ្ញាតឲ្យមេធាវីរបស់ខ្ញុំគឺលោក អាង ឧត្តម និងលោក ម៉ៃឃើល ខាណាវ៉ាស់ (Michael G. Karnavas) ការពារក្តីលោក មាស មុត។

សូមទទួលការគោរពអំពីខ្ញុំ

-------------------------

អៀង សារី

15 មិថុនា 2012

# WAIVER

## IENG SARY'S WAIVER OF ANY POTENTIAL CONFLICT OF INTEREST

I, Mr. IENG Sary, hereby voluntarily, knowingly and unequivocally waive any potential conflict of interest which may arise because of my counsel Mr. Ang Udom and Mr. Michael G. Karnavas's representation of Mr. Meas Muth. During the temporal jurisdiction of the ECCC I never had any association, either directly or indirectly, with Mr. Meas Muth. In executing this waiver of any potential conflict of interest, I fully understand that I am also waiving any potential points of appeal that might possibly arise, however tangentially, by having my counsel, Mr. Ang Udom and Mr. Michael G. Karnavas also represent Mr. Meas Muth.

Respectfully submitted,

[signature]

______________________

IENG Sary

15 June 2012